# ការសំភាសន៍ជាលើកទី២របស់បងស្រី ង៉ សីហា

កះ អ្នកសំភាសន៍ឈ្មោះញ៉ែម សុគន្ធា ខះអ្នកត្រូវសំភាសន៍ឈ្មោះ ង៉ សីហា

## <u>ការសង្ខេបរបស់ឈ្មោះង៉ សីហា</u>

នៅក្នុងការសំភាសន៍ជាលើកទី២នេះបងស្រីបានរៀបរាប់ពីជីវិតដែលត្រូវឪពុកម្ដាយបានស្លាប់ចោលគឺគាត់ត្រូវរស់នៅជាមួយយាយចិញ្ចឹមដែលបានសុំគាត់ពីបងប្អូនហើយគាត់រស់នៅជាមួយយាយត្រូវយាយធ្វើបាបវ៉ៃដោយសារយាយនោះគាត់កាចហើយដោយសារអត់បាយហូបពីមុនគាត់មករស់នៅជាមួយយាយគាត់បានហូបបាយផ្អូមដោយយកវាទៅលាងទឹកហើយយកទៅបបរ។គាត់ថាពេលនៅជាមួយឪពុកម្ដាយគាត់ពេលគាត់នៅរស់គឺគាត់ពុំពិបាកទេតែពេលគាត់ស្លាប់ទៅគឺគាត់ពិបាកយ៉ាងខ្លាំង។
បងស្រីបានរៀបការហើយក៏ចាកចេញពីយាយចិញ្ចឹមហើយរស់នៅជាមួយស្វាមីគឺគាត់បានស្វាមីដែលស្រលាញ់គាត់ហើយគាត់ពុំពិបាកទេពេលរៀបការហើយគឺនៅផ្ទះមើលកូន
ហើយគាត់មានកូនជាអ្នករាំហើយអ្វីដែលលំបាកឥឡូវគឺគាត់មានកូនម្នាក់បានជាប់គុក
ដោយសារតែជក់គ្រឿងញៀន។

កះអូខេជាដំបូងនាងខ្ញុំសូមថ្លែងអំណរគុណដែលអោយញ៉ុមសំភាសន៍អំពីជីវប្រវត្តិរបស់បងស្រីជាលើកទៅ២នាងខ្ញុំឈ្មោះញ៉ែមសុគន្ធាជាអ្នកសំភាសន៍អំពីជីវិតរបស់បងនៅក្នុងថ្ងៃនេះពួកយើងសំភាសន៍គឺនៅក្នុងខែកុម្ភៈអើរនៅក្នុងខែមិនាឆ្នាំ២០១៨ការសំភាសន៍នេះមានទីតាំងស្ថិតនៅក្នុងភូមិព្រែកហូរខាងលិចសង្កាត់ព្រែកហូរក្រុងតាខ្មៅខេត្តកណ្ដាល!!ហើយពួកយើងនិងចាប់ផ្ដើមសួរអំពីជីវប្រវត្តិរបស់បងជាបន្តទៀតដោយសារពេលមុនញ៉ុមបានសួរខ្លះៗអំពីជីវិតរបស់បងតែអត់ទាន់បាននៅគ្រប់នូវអ្វីដែលបងមានសំរាប់ប្រាប់ទៅកូនចៅជំនាន់ក្រោ យ
អ៊ិចឹងបងសូមប្រាប់ឈ្មោះពេញ? ឈ្មោះពេញហាំ?
ខះ ញ៉ុមហេ ង៉ សីហា។
កះ អ៊ីចឹងបងឥឡូវចូលដល់ការសិក្សាដោយសារពេលមុនគឺភាគច្រើនគឺសួរតែខ្លួនឯងបន្តិចបន្តួចនឹងអំពីប្រវត្តិម៉ែឪនឹងការលេងជាមួយបងប្អូនអ៊ីចឹងទៅណាស់បង?
ខះ ចាំចាំ!!
កះ អ៊ីចឹងណាស់បង!!អ៊ីចឹងតើបងរៀន តើការសិក្សារបស់បងបងរៀនបានថ្នាក់ទីប៉ុន្មានដែរ?
ខះ អត់អត់បានរៀនផង។
កះ ម៉េចបានអត់បានរៀនមូលហេតុអីគេ?

ខ៖ អត់បានរៀន។
ក៖ និយាយទៅពីនៅទូចមក!!
ខ៖ ហ្នឹងតាំងពីទូចរហូតដល់ធំអត់បានរៀនតែម្តងរាល់ថ្ងៃមានចេះអក្សរណា!!
ក៖ ម៉េចអ៊ីចឹងដោយសារជីវភាពមែនបានអត់ទៅរៀនអញ្ចឹងបង?
ខ៖ហ្នឹងហើយម៉ែឪអត់សូវមានលុយហើយណាមួយគាត់ក្រ។ក៖ចាំ!!ខ៖ដាក់រៀនហើយតែរៀនរៀនដូចអត់រៀនអត់នេះអត់ពូកែ ខ្ជិលឈប់រៀនទៅ។
ក៖ តែបានចូលសាលាដែរមែនទេ?
ខ៖ ចូលសាលាថ្នាក់ទី១ហ្នឹង ថ្នាក់ទី១រហូត។
ក៖ អត់មានឌុបអត់មានអីទេ គ្រាន់តែបានចូលរៀនបានប៉ុន្មានខែ?
ខ៖ អត់ទេ!!
ក៖ អ៊ីចឹងទៅហី?
ខ៖ ហ្នឹងហើយ។
ក៖ ហើយដល់ពេលដោយសារបងរៀនអត់សូវចេះបងឈប់រៀនម៉ងទៅ?
ខ៖ ចាំ។
ក៖ អ៊ីចឹងបងកាលបងរៀនបងរៀននៅសាលាបឋមសិក្សាណាដែរ?
ខ៖ រៀននៅខេត្តកំពង់ឆ្នាំងយើងហ្នឹង។
ក៖ ចាំឈ្មោះសាលាទេ?
ខ៖ ហ៊ីសាលា សាលាគេហៅវត្តសំរោង។
ក៖ នៅកំពង់ឆ្នាំងហ្នឹងបងនៅជិតភ្នំនាងកង្រីឬក៏អត់?
ខ៖ ភ្នំកង្រីនៅផ្សារនៅជិតដែរ តែយើងដូចថារបៀបថាត្រឹមប្រវែងយើងទៅផ្សារដែរតាខ្មៅហ្នឹងដែរហ្នឹង!!
ក៖ហ្ហ៎!!តែមើលឃើញភ្នំតើបងហី?
ខ៖ ឃើញ ឃើញ មើលពីចំងាយទៅឃើញម៉ង។
ក៖ បងឯងមានដឹងប្រវត្តិនាងកង្រីអីខ្លះទេ?គេមានដែលនិយាយអី?
ខ៖ អត់ទេ!! ប្រវត្តិដែលគ្រាន់តែគេនិយាយថាយើងនៅណោះគេអត់ស៊ីម្អមអត់ស៊ីអីអ៊ីចឹងណាស់ ។
ក៖ ម៉េចទៅបងបងឯងនិយាយរឿងមួយហ្នឹងបន្តិចមើល?
ខ៖ នៅហ្នឹងគេអត់ហូបម្អមទេ ពេលហូបម្អមឈឺក្បាលណាស់!!
ក៖ គ្រប់គ្នាទាំងអស់ម៉ងហោ?

ខ៖ ចាំ!!ដល់ពេលញ៉ុមមកនៅ មកនៅជាមួយប្ដីញ៉ុមនេះគេស្លរបង់ម្អម ញ៉ុម
អូយធំក្លិនអាក្រក់ណាស់ ញ៉ុមអត់ហូបទេ ធំអាក្រក់ណាស់។
ក៖ចាំ!!
ខ៖ ដល់ពេលឥឡូវអត់ទេ ធម្មតាហូប ហូបធម្មតាហូបជាមួយគេជាមួយឯងចេះទៅ
កាលនៅណោះញ៉ុមស្លរ ញ៉ុមអត់ដែលដាក់ម្អមទេ ស្លរម្ជូរស្លរអីអត់ដែលដាក់ម្អម ស្លរម្ជូរ ម្ជូរម៉ង
អត់ដែលដាក់ម្អមដាក់អីអត់ប្រើម្អមម៉ង មមុីសនាងកង្រើៗ!!
ក៖ ភាគច្រើនអ្នកនៅហ្នឹងគឺជឿរឿងមួយហ្នឹងខ្លាំងម៉ង!!
ខ៖ គេអត់ហូបម៉ង គឺជឿមែនហាំវាមែន ប្រហែលវាមែនបានគេជឿហ្វូំ!!
ក៖ តែវារាប់រយឆ្នាំហើយល្មមនេះហើយអា!!
ខ៖ ហ្នឹងហើយ ហ្នឹងហើយ។
ក៖ ល្មមឈប់អាទំនៀមទំលាប់អាថាគិតថាអិចឹងហាំ!!
ខ៖ តែឥឡូវគ្មានទេ ឥឡូវគេហូបគ្រប់តែគ្នា។
ក៖ អីចឹងនៅណោះឥឡូវគេហូបវិញហើយហោ?
ខ៖ ឥឡូវគេហូបវិញហើយកំពង់ឆ្នាំងឥឡូវគេដាំម្អមយកមកលក់យកមកអីស្លរដាក់គ្រប់គ្នាដែរ
ហើយឥឡូវ ពីមុនអត់ទេ អត់ដែលហូបទេ។
ក៖ តែនៅលើភ្នំកង្រើហ្នឹងសំបូរម្អមដុះមែនហោបង?
ខ៖ អូ!!មិនបាច់និយាយទេច្រើនណាស់ញ៉ុមទៅលេងកបិនលេងអីជិះទូកទៅហាំនាំពួកម៉ាក
ញ៉ុមទៅហែរកបិនហើយខែនេះហើយទៅដល់ទៅដកម្អមលើភ្នំនិយាយពីម្អមដាក់បាវមិនអស់
ដកសុទ្ធតែម្អម។
ក៖ ម្អមនៅលើភ្នំ?
ខ៖ ហ្នឹងហើយ និយាយរួមតាមណាក៏មានដែរ អោយតែថាកន្លែងភ្នំកង្រើហ្នឹង
កន្លែងណាក៏មានដែរ។
ក៖ ចំ!!
ខ៖ សុទ្ធតែម្អមម៉ង។
ក៖ ញ៉ុមឆ្ងល់ថាមូលហេតុអីបានវាទៅដុះនៅពេញហ្នឹង?
ខ៖ វាអត់ដឹងហ្នឹងហាំ!!ម្អមម្អមនៅហ្នឹង។
ក៖ សូម្បីតែនៅលើភ្នំក៏មានដុះដែរ?
ខ៖ ដុះកន្លែងណាក៏មានដែរ ដុះតាមជាយៗភ្នំហ្នឹង។
ក៖ ធម្មតាម្អមដុះនៅតែក្នុងស្រែទេ ដល់ពេលមកដុះនៅលើភ្នំហ្នឹង!!

ខ៖ ហ្នឹងហើយដុះនៅលើវាលស្រែគេនៅជិតៗហ្នឹង ជិតភ្នំហ្នឹង
គេធ្វើស្រែធ្វើអីហ្នឹងមិននៅជិតហ្នឹងទាំងអស់ ស្មៅអីនៅហ្នឹង ម្អមឈ្ងុយណាស់នៅហ្នឹងហាំ !!
ក៖ ចាំ!!
ខ៖ម្អមក្រហមៗអង្គារដីទូចៗទេ ម្អមមិនដូចយើងឥឡូវទេ ម្អមអាម្អមយើងធំៗណោះ
អាហ្នឹងអត់ឆ្ងាញ់ទេ!!តែម្អមនោះឈ្ងុយម៉ង គ្រាន់តែយើងដើរ មិនបាច់បេះទេ
គ្រាន់តែយើងនៅឆ្ងាយអ៊ិចឹងភាយ ធំម្អមភាយៗធំម្អមឆ្ងាញ់ណាស់។
ក៖ តែពេលជំនាន់បងឯងនៅពីក្មេងអ៊ីចឹងពេលម្អមធំក្លិនឈ្ងុយអ៊ីចឹងគេថាអត់ឈ្ងុយទេមែន
ទេ?
ខ៖ អត់ទេ!!
ក៖ គេថា!!
ខ៖ ទៅស្អុយវិញ មិនដែលហូបមិនដែលដាក់សំលផងហ្នឹង
ហើយញ៉ុមហូបទៅអោយតែបង់ម្អមឈឺក្បាលហើយ ហើយអត់ចង់ហូបទេ។
ក៖ ដោយសារផ្នត់គំនិតហើយការគិតវាអញ្ចឹងមកដល់ពេលអញ្ចឹងនាំអោយមនុស្សអ៊ីចឹងទៅ?
ខ៖ តែឥឡូវគេហូបគ្រប់គ្នាហើយតើ!!
ក៖ ហ្នឹងហើយ ចាំ!!
បងចុះពេលបងនៅរៀនហាំបងមានមិត្តភក្តិអីជិតស្និតទេពេលហ្នឹងពេលនៅរៀន?
ខ៖ ញ៉ុមពេលនៅរៀនគ្មានទេ នៅក្មេងទូចៗដូចគ្នា គ្មានដែលនេះទេភ្លេចអស់ហើយ
មានដែលនេះធំឡើង បានពួកញ៉ុមក្រមុំៗ ប៉ុនមិត្តភក្តិក្រមុំក្រមុំនៅជិតផ្ទះអីអ៊ីចឹងទៅណាស់!!
ក៖ ចាំ!!
ខ៖ ៣ ៤នាក់ ៤ ៥ នាក់អីអ៊ីចឹងហាំ!!នាំគ្នាដើរលេងដើរអីអ៊ីចឹងទៅ!!
ក៖ ចាំ!!
ខ៖តែញ៉ុមមិនមែននៅជាមួយពេលដែលម៉ែឪញ៉ុមស្លាប់ទៅអញ្ចឹងមានគេនៅជិតខាង
យាយចិញ្ចឹមហាំគាត់ប្រហែលចំណាស់យាយកាននេះគាត់ចង់ចំណាស់អត់ដល់យាយកានទេ
គាត់អត់ដើរកោងៗដូចគាត់ទេណាស់ គាត់រៀងរៀសរវន់ជាងយាយកានហាំ!!
គាត់មិនមែនដូចជាយាយកានដើរទន់ដៃទន់ជើងអញ្ចឹងទេ!!
ក៖ ហ៊ឺៗ!!
ខ៖ គាត់រៀសជាង ដល់ពេលអញ្ចឹងគាត់សុំញ៉ុមទៅនៅជាមួយអ៊ីចឹងទៅណាស់
យកទៅនៅជាមួយគាត់អ៊ីចឹងគាត់ដាំបាយដាំអី គាត់លក់បាយលក់អីតាម តាមផែទឹក
តាមកំពង់ឃ្លាំង លក់បាយដាក់ចង់ដាក់អីអញ្ចឹងទៅណាស់!!

កៈ ចាំ!!
ខៈ មួយថង់៥០០ មួយថង់៥០០អីចឹងទៅ បាយសំលរអីអីចឹងទៅណាស់ ជួយលក់គាត់ទៅ ទៅនៅជាមួយគាត់ទៅតាំងពីទូច គាត់ចិញ្ចឹមយើងម៉ែឪស្លាប់ចោលហ្នំ!!
កៈ ចាំ!!
ខៈហើយពួកម៉ាក់ញុំមគេចេះតែចូលឆ្នាំអីចឹងគេបបួលដើរលេងដើរអីអញ្ចឹងមិនដែលបានដើរលេងទេយាយហ្នឹងវ៉ែវ៉ែញ៉ុមហាំ!!វ៉ែញ៉ុមថាអត់អោយដើរលេងទេតែហ៊ានដើរលេងអញវ៉ៃង៉ែងងាប់ម៉ង ហ្នឹងមិនដែលបានដើរលេងទេ នៅជាមួយគាត់?
កៈ បងឯងអាយុបានប៉ុន្មានឆ្នាំបានមកនៅជាមួយយាយហ្នឹង?
ខៈ អាយុប្រហែលជា១៣១២អីហើយត្រើសហើយរាងធំហើយ១២១៣ហើយបាននៅជាមួយគាត់ហ្នំ!! មិនដែលបានដើរលេងទេ ហ៊ានតែដើរលេងគាត់វ៉ៃ!!
កៈ ចាំ!!
ខៈ ហើយបើថាគាត់ប្រើយើងអើរប្រើចង់ទៅទិញអីមួយអីចឹងគាត់ស្ដោះទឹកមាត់ហាំ!!ចាស់ពីដើមអាក្រក់ណាស់ស្ដោះទឹកមាត់ហ្នឹងឆាច់ទឹកមាត់ហ្នឹងតែស្ងួតតែស្ងួតមកវិញដឹងតែត្រូវហើយហ្វយប្រើទៅរត់ហើយរត់ឡើងបែកញើសហូរញើសទៅអញ្ចឹងទៅមកវិញអាហ្នឹងទឹកមាត់វាមិនទាន់ស្ងួតទេណាស់ ជិតស្ងួតដែរអត់វ៉ៃទេ ដល់សារក្រោយប្រើទៀតហាំ រត់ទៅទៀតហើយចុះតាមរោងកាហ្វេគេមិនដាក់រឿងខ្មោចរឿងអីមើល !!
កៈហ៊ុំៗ!!
ខៈរត់បណ្ដើរចង់មើលរឿងខ្មោចគេថាខ្មោចឆៅខ្មោចឆៅយើងដល់ពេលអញ្ចឹងហោអញមើលខ្មោចឆៅសិនហើយហាំ!!ឈរមើលនៅរោងកាហ្វេឈរមើលនៅក្រៅអីចឹងហិ!!គេផឹកកាហ្វេយើងឈរក្រៅ ក្មេងហ្នំ!!ឈរមើលទៅសើចៗឈរមើលភ្លេចខ្លួនហ្នំ!!យាយប្រើយូរអញ្ចឹងហាំ !!
កៈ ចាំ!!
ខៈ យាយចាំអើយយករំពាត់ដាក់លើគ្រែមកវ៉ៃហើយមកវ៉ៃហើយគោះគ្រែហ៊ុមីហ្នឹងទៅយូរណាស់ សារហ្នឹងប្រើវាមិនដឹងវាទៅដល់ណាទេយូរណាស់ដល់ពេលនឹកឃើញអូយយាយវ៉ៃហើយអញ យូរណាស់គិតទៅមួយម៉ោងអាលែងតែមើលរឿង មកផ្ទះអត់ហ៊ានចូលផ្ទះទេលបៗ ហ្នំចាំមើលហើយយាយហ្នំអត់ហ៊ានដេកទេ យាយចិញ្ចឹមញ៉ុមហ្នឹងហាំ អត់ហ៊ានដេកទេមើលតែមកវ៉ៃមកម៉ង»!!លបៗចូលផ្ទះ ង៉ែងទឹមមកពីណា?អញប្រើង៉ែងមួយថ្ងៃហើយណាស់ប្រើទៅទិញស្អីគេទេកាលហ្នឹង មកដល់មានអីហ្វែងវ៉ៃយកវ៉ៃយកឡើងកន្ទួលសាច់យំជិតងាប់ថ្ងៃក្រោយរាងរហូត។
កៈ លែងមើលរឿងទៀត!!

ខ៖ ហើយអាលុយមួយកាក់ពីរកាក់យើងហ្នំ ពីមុននោះ លុយមួយកាក់ពីរកាក់យើងយក បើយើងទិញស្ករគ្រាប់បានតែមួយគ្រាប់ទេ អត់ស្ករគ្រាប់ហូបហាំ ជូនកាលវារហៀក វារហៀកជាពីរអ៊ិចឹងគាត់ទុក អាណារហៀករហៀកគាត់ទុកបិតហាំ!!!បិតយកស្កុតបិតហើយ ជូនកាលឃ្លានអញ្ចឹងហាំទៅយកអាមួយកាក់ហ្នឹងបិតហើយមកបិតបិតបាយយកទៅទិញស្ករ គ្រាប់ បាត់ក៏ដឹងដែរ យាយហ្នឹងពូកែដឹងណាស់ បិតអ៊ីចឹងទៅទៅទិញស្ករគ្រាប់វិញ មកវិញដឹងតែវ៉ៃហើយ ។

ក៖ ចាំ!!

ខ៖គាត់ថាហ្អែងហ្អែងលួចលុយហើយឃើញទេ?លួចលុយអស់មួយកាក់យកទៅទិញស្ករគ្រាប់ ហើយ ហ៊ីញ៉ុមហេរពេកញ៉ុមយកលុយអារហែកយកទៅបិតហ្នំទៅទិញស្ករគ្រាប់ហូបហ្នំ!!

ក៖ ចាំ!!

ខ៖ កាលនៅពីទូចហ្នំ!!គាត់វ៉ៃជិតងាប់ជិតរស់ទៀត!!ហើយក្បាលមួយអំបោះក៏ឃើញដែរនៅ ជាមួយគាត់ហ្នំ!!វ៉ៃដល់ពេលគាត់ស្លាប់ទៅគាត់ស្មាទោសញ៉ុមដែរហ្នឹងគាត់ស្លាប់នៅវត្តសំបួរមា សនៅភ្នំពេញនេះ។

ក៖ ហ្នឹងហើយ។

ខ៖គាត់ថាកុំអោយគាត់មានកម្មពៀរជាមួយញ៉ុមព្រោះថានៅពីទូចគាត់ចិញ្ចឹមញ៉ុមមែនតែគាត់ ធ្វើបាបញ៉ុម។

ក៖ ហើយគាំតម៉េចទៅចិត្តអ៊ីចឹងម៉េចទៅធ្វើបាប??

ខ៖ ព្រោះគាត់កាច យាយហ្នឹងគាត់កាចណាស់ ហ្នឹងហើយគាត់កាច!!

ក៖ ហ្នឹងហើយ ចិត្តអ៊ីចឹងម៉ងហេ?ហើយគាត់មានកូនមានចៅអីទេ?

ខ៖កូនគាត់មានតែម្នាក់ទេតែនៅជាមួយគាត់អត់កើតទេដេរកូនម៉ែហើយនឹងកូនហ្នឹងដេរគ្នាដូច នេះ ដេរអ៊ីចឹងដូចអ្នកដទៃអ៊ីចឹង ម៉ែដេរកូន កូនដេរម៉ែដូចស្វិអ៊ីចឹង!!

ក៖ ហ៊ឺៗ!!

ខ៖ កូនដេរទៅដេរមក ហើយកូនហ្នឹងរាងចំណាស់ដែរហ្នំ!!

ក៖ ហ៊ឺៗ!!

ខ៖ដេរទៅដេរមកជាមួយម្ដាយហ្នឹងមកហើយកូនស្រីគាត់ហ្នឹងតែហើយនិយាយទៅយាយហ្នឹង កាចម៉ងហាំ!!កាចម៉ងនៅជាមួយគាត់អត់បានទេហើយបើយើងទៅដើរលេងដើរអីក៏អត់បានដែ របើពួកម៉ាក់ញ៉ុមមកលេងអ៊ីចឹងហាំចូលឆ្នាំអ៊ីចឹងមកបបួលញ៉ុមចង់អោយញ៉ុមទៅដើរលេងជាមួ យពួកវាអ៊ីចឹងហាំ!!

ក៖ ហ៊ឺៗ!!

ខ៖ អោយបានដើរលេងសប្បាយទាំងអស់គ្នាអឺចឹងហា៎!! ទាល់តែមកថាសុំយាយ
យាយអើយញ៉ុមសុំអង្វរយាយអោយសីហាទៅលេងជាមួយញ៉ុមមក ? អត់អោយទៅទេ !!
មកមួយទៀតហើយសុំមួយទៀតហើយ៣៤នាក់មកសុំអញ្ចឹងហា៎!!អោយវាធ្វើការហ្នឹងអោយ
ហើយបានអោយវាទៅអញ្ចឹងទៅពួកហ្នឹងជួយធ្វើញ៉ុមហើយហើយញ៉ុមលក់បាយញ៉ុមជួយលក់
បាយគាត់ហ្ន៎!!ជួយធ្វើពូកពាកពូកពាកអឺចឹងទៅហា៎!!លេងកំនត់ម៉ោងទៀតអោយយើងត្រូវម៉ោ
ងប៉ុន្មានអោយមកផ្ទះវិញកុំអោយទៅលេងដូចថាកុំអោយវាស់ល្ងាចដូចថាវាស់ល្ងាចអីណាស់
ដូចថាត្រឹមម៉ោង៣ម៉ោង៣ម៉ោង៤ម៉ោង៤ដើរលេងអីទេណាស់!!
ក៖ហុឹៗ!!
ខ៖បុណ្យចូលឆ្នាំអីហ្នឹងយើងដើរលេងអឺចឹងកំនត់ម៉ោង១ម៉ោង២រាំអីអញ្ចឹងក៏ដោយជិតៗផ្ទះដូច
ដើរលេងពេលយប់អញ្ចឹងណាស់ វត្តជិតៗផ្ទះ!!
ក៖ ចា៎!
ខ៖ និយាយទៅគាត់អត់អោយយើងដើរលេងក៏ល្អដែរចាស់ពីដើមគាត់មិនសូវអោយយើង
ដើរលេងទេ។
ក៖ ហើយបងនៅជាមួយគាត់បានប៉ុន្មានឆ្នាំបានគាត់ស្លាប់ទៅ?
ខ៖ គាត់ទឹមតែស្លាប់ទៅប្រហែល ប្រហែលជា៤ ១០ឆ្នាំអីទេនេះហ៎។
ក៖ អឺចឹងពេលបងមុនបងការហ្នឹងគាត់អ្នកធ្វើម៉ែឪអោយ?អឺចឹងហេ?
ខ៖ ហ្នឹងហើយមានតែយាយគាត់ធ្វើអោយ។
ក៖ អឺចឹងពីបងឯងដល់ពេលបែកពីបងប្អូនមកបានមកនៅជាមួយយាយនឹងទៅ?
ខ៖ ហ្នឹងហើយ។
ក៖ ហើយនៅជាមួយយាយនឹងទៅ?
ខ៖ ហ្នឹងហើយ។
ក៖ ចា៎ថានៅប្រហែលជាបានប៉ុន្មានឆ្នាំទេបានរៀបការ?
ខ៖ ញ៉ុមហេ?
ក៖ ហ្នឹងហើយ។
ខ៖ បែកពីយាយ អើរបែកពីម៉ែញ៉ុមហេ?
ក៖ ហ្នឹងហើយ
ខ៖ អូយញ៉ុមក្រមុំហើយនឹង។
ក៖ បានមកនៅជាមួយគាត់ហេ?
ខ៖ ហ្នឹងហើយ បានមកនៅជាមួយគាត់!!

កៈ ហើយមកនៅប៉ុណ្ណឹងហើយនៅតែនៅធ្វើបាបទៀត?

ខៈ នៅធ្វើបាប គាត់មើលថែទាំយើងហាំ។

កៈហ្នឹងហើយចាំអ៊ិចឹងបងចូលដល់ក្តីស្រម៉ៃរបស់បងហាំ?ដូចជាពីក្មេងមកគិតថាធំឡើងចង់ធ្វើអីមួយអីអត់?

ខៈ គិតធ្វើចង់ធ្វើតែទាំងអស់ហ្នឹងតែគិតចង់ធ្វើ ថាយើងអត់ចេះអក្សរយើងទៅធ្វើអីគេកើត។

កៈ តែស្រលាញ់អីគេជាងគេនៅក្នុងជីវិត?មុខរបរ?

ខៈ មុខរបរញ៉ុមបើញ៉ុមនៅជាមួយយាយយាយចិញ្ចឹមញ៉ុមគាត់បង្រៀនជួយលក់បាយលក់អីហ្នឹងទៅ បាយសំលអីហ្នឹងដាច់ហាំ ដាច់ដូចថាតាមុខរោងចក្រតាមទូកតាមផែត្រីអីអ៊ីចឹងទៅយើងលក់ដាច់ចំនេញច្រើនអីអ៊ីចឹងហាំ!!មុខរបរញ៉ុមយើងនៅជាមួយយាយយើងមានមុខរបរអីយើងអត់ចេះអក្សរ!!

កៈ ហ៊ី!

ខៈ គេមានតែមុខរបរហ្នឹងហើយ យើងលក់បាយលក់អីអញ្ចឹងទៅវាដាច់។

កៈ ចាំ អញ្ចឹងឃើញបានលុយដោយសារអាហ្នឹងទៅក៏ស្រលាញ់ចង់លក់ដូរ។

ខៈហ្នឹងហើយនឹកឃើញថាយាយគាត់ថាអញ្ចេកសីហាអត់ពីអញទៅហាំឃើញទេមុខរបរលក់បាយហិសម្លរចេះស្លរ៧៨មុខមានសាច់ចៀនមានមាន់ចៀនអីអញ្ចឹងទៅណាស់អត់ពីអញទៅង៉ែងមានមុខរបរហ្នឹងហើយរកស៊ីទៅ

មុខរបរហ្នឹងអត់ខាត់ទេមុខរបរហ្នឹងរកស៊ីទៅវាមានហើយ!!

កៈ ចាំ!!

ខៈព្រោះលក់បាយលក់អីអញ្ចឹងយើងអត់ចេះអក្សរអ៊ិចឹងហាំ!!នឹកឃើញថាយើងអត់ចេះអក្សរមានតែមុខរបរអញ្ចឹងហើយមានទៅធ្វើការអីកើតនឹងគេយើងអត់ចេះអក្សរផងហ្នឹងមានតែមុខរបរលក់បាយលក់អីអ៊ីចឹងយើងចិញ្ចឹមទៅយើងវាគ្រាន់តែឥឡូវមុខរបរតែឥឡូវវាអត់មានលុយទៀតហាំ !! យើងចង់លក់អីក៏វាអត់មានលុយដែរ ឥឡូវហ្នឹងហិ!!

កៈ ចាំ!!

ខៈ ចង់លក់មុខរោងចក្រចង់លក់មុខអីអញ្ចឹងហាំ!!វាអត់លុយ។

កៈ ហើយចុះម៉េច យាយម៉េចបានជាគាត់ឈប់លក់ហ្នឹង ដោយសារគាត់ចាស់ទៅហី?

ខៈ ពេលគាត់ចាស់ទៅញ៉ុមការហើយអីអញ្ចឹង។

កៈ បងឯងមិនព្រមស្នងមុខរបរហ្នឹង?

ខៈ និយាយរួមញ៉ុមការហើយធ្វើអត់កើតទេម្នាក់ឯងព្រោះម្ហូបច្រើនម្ហូបច្រើនហើយបាយក្នុងមួយថ្ងៃយើងដាំជិត២០គីឡូណោះហ្នឹង!!

កៈ អូយច្រើនណាស់អ៊ិចឹងបង?
ខៈ ចា៎ ដាំឆ្នាំងធំណាស់ មកតាមកាណូតហា៎!! កាណូតគេដឹកពោតគេដឹកអីហ្ន!!តាមផែត្រីហា៎ គេឡើងពីទូកមកច្រើនៗណាស់!!
កៈ ហ្នំពេលហ្នឹងបើមានគ្នាលក់មិនក្រទេនេះ!!
ខៈ លក់បើសិនជាលក់ ណាមួយគាត់ចាស់ គាត់ធ្វើមិនកើតផង ហើយណាមួយញ៉ុមការ ញ៉ុមការញ៉ុមឈប់នៅជាមួយគាត់ ប្តីញ៉ុមហ្នឹងហៅឡើងមកនៅភ្នំពេញនឹកឃើញថា នៅជាមួយយាយគាត់ធ្វើបាបធ្វើអីអីចឹងទៅណាស់!!
កៈ ហ៊ឺៗ!!
ខៈ ថាការហើយកុំអោយនៅធ្វើបាបអីចឹង
គាត់ថាបើយើងឡើងមកភ្នំពេញបើយើងមានលុយមានកាក់អីយើងបើករកស៊ីខ្លួនឯងទៅ។
កៈចា៎!!
ខៈ ដល់ពេលអត់ក៏អត់ដល់ឥឡូវហ្នឹងទៅ។
កៈ អ៊ីចឹងដល់ពេលបងឯងចេញពិយាយមកយាយនៅតែម្នាក់ឯងទេអ៊ីចឹង?
ខៈ យាយនៅម្នាក់ឯង ហើយគាត់ក៏លក់ផ្ទះហ្នឹងបានមួយដំឡឹង
បានមួយដំឡឹងក៏គាត់បានឡើងមកនៅភ្នំពេញដែរ
គាត់ឡើងមកភ្នំពេញគាត់បានទិញតូបយើងអានៅវត្តសំបួរមាសយើងនេះ ស្ពានីយ៍បូមទឹកនេះ ស្គាល់វត្តសំបួរមាសទេ?
កៈ ស្គាល់ នៅស្ទឹងមានជ័យជិតស្ទឹងមានជ័យហ្នឹង!!
ខៈ ហ្នឹង ហ្នឹងហើយ គាត់ទៅនៅហ្នឹង គាត់លក់ផ្ទះដែរ។
កៈ ហ៊ឺៗ!!
ខៈ គាត់លក់ផ្ទះបានមួយដំឡឹង ផ្ទះគាត់ធំណាស់ លក់គាត់អត់ចែកញ៉ុមទេ ដូចថាញ៉ុមនៅជាមួយគាត់!
កៈ ចិត្តអាក្រក់ម្ល៉េះ។
ខៈតាំងពីរស់នៅជាមួយគាត់ជួយលក់គាត់មួយនេះហា៎និយាយមែនអត់មានចែកញ៉ុមទេដល់ពេលគាត់លក់គាត់អីបានគាត់ទៅទិញតូបនៅហ្នឹងគាត់នៅតែឯងហ្នឹងឥឡូវគាត់ធ្លាក់ខ្លួនគាត់ កើតទៀចទឹកហ្នំ!!គាត់ដឹងជំងឺគាត់គាត់អត់ហូបស្រាទេ តែគាត់មិនដែលហូបស្រាទេ តែគាត់កើតទៀចទឹកគាត់ស្លាប់ទៅ!!
កៈ ហ៊ឺៗ!!

ខ៖ហើយតួបនឹងតល្ងរគាត់ទិញនៅនឹងវត្តហ្នឹងគាត់អោយទៅយាយតទៅទៀតដូចថាមុនគាត់ស្លាប់ទៅ គាត់អោយទៅយាយៗដែលនៅជិតៗហ្នឹងដែលអត់ៗ គាត់អោយតអីចឹងទៅណាស់!!
ក៖ តួបហ្នឹងតួបនៅតើហីមិនមែនតួបរកស៊ីណាហី?
ខ៖ តួបហ្នឹងនៅរាល់ថ្ងៃ តួបតួបយាយជី យាយជីរបៀបនៅក្នុងវត្ត ។
ក៖ហ្ហ៎!!
ខ៖ដូចថាជីនៅម៉ាជុំវិញវត្តអីចឹងបើយាយជីគាត់មានលុយគាត់មានអីគាត់ទិញធ្វើតួបនៅក្នុងវត្តអីចឹងដូចថាផ្ទះគាត់ហ្នឹងនៅនៅមួយគ្រែអីចឹងទៅទៅតែឯងអីចឹងទិញជីលោកអិចឹងហា៎!!លោកអោយនៅអិចឹងទៅ!!
ក៖ ហ្ហ៎!!
ខ៖ ដល់ពេលយើងស្លាប់ទៅអីចឹងទៅទុក
យើងអោយអាណាអោយទៅស្រេចយើងមានសទ្ធាអីអិចឹងទៅណាស់!!
ក៖ ចា៎!!អញ្ចឹងបងចូលដល់ជីវិតអាពាហ៍ពិពាហ៍វិញម្តង
អូខេអិចឹងបងចូលដល់ជីវិតអាពាហ៍ពិពាហ៍បងរៀបការជាមួយស្វាមីគាត់ឈ្មោះអីគេដែរបង?
ខ៖ គាត់ឈ្មោះ ហ៊ុយ នី។
ក៖ ហ៊ុយ នី?
ខ៖ចា៎!!
ក៖ ឥឡូវស្វាមីបងគាត់អាយុប៉ុន្មានឆ្នាំហើយ?
ខ៖ គា់តអាយុ៥៤ហើយ។
ក៖ ចា៎ អិចឹងបងរបស់បង៥ឆ្នាំ?
ខ៖ ហ្នឹងហើយ ៥៤។
ក៖ អីចឹងបងតើស្វាមីរបស់បងគាត់អ្នកស្រុកមកពីណាដែរបង?
ខ៖ គាត់មកពីខេត្តកោះធំ!!
ក៖ ហ្ហ៎!!ស្រុកកោះធំហី?
ខ៖ ហ្នឹងហើយ។
ក៖ ស្រុកកោះធំ ខេត្តកណ្តាលយើង។
ខ៖ ហ្នឹងហើយកោះធំ។
ក៖ ចុះពេលមុនហ្នឹង ពេលបងឯងរៀបការហ្នឹងបងឯងឆ្នាំដែលរៀបការហ្នឹងទេ?ចា៎អត់?
ខ៖ អត់ចាំផង ទាល់តែប្តីញ៉ុមបានចាំ។
ក៖ ឥឡូវការបានប៉ុន្មានឆ្នាំហើយ មកទល់នឹងសព្វថ្ងៃហ្នឹង?

ខ៖ តែមើល កូនញ៉ុមអាបង ២០ជាងហើយ។
ក៖ ចំច្រើនហើយហើយនឹង!!
ខ៖ ចា៎!!
ក៖ តែ២០ជាងហ្នឹងមានទូចមួយទៀត។
ខ៖ ហ្នឹងហើយ ថាអញ្ចេកថាបានកូនស្រីតែវាមកកូនប្រុស។
ក៖ហ្ហ៎!!
ខ៖កុំអីអត់ត្រូវយកទេដល់ពេលអត់ត្រូវយកវាទេដល់ពេលយល់សប្តិឃើញថាចំកូនស្រីមកសុំនៅម៉េចមកដល់ពេលកើតកូនប្រុសនេះឆ្ងល់ដល់ហើយនេះ អញ្ចឹងបានថាទុកហ្នឹងហា៎!!
ក៖ ហ្នឹងហើយ។
ខ៖ កុំអីអត់យកទេ!!
ក៖កុំអីអត់មានឃើញប្រុសហ្នឹងមកទេ!!អូយក្រឹតកូនហ្ហ៎!!អញ្ចឹងប្រហែលញ៉ុមគិតថាមុនឆ្នាំ២០០០អីហ្នឹងបើថាមុនឆ្នាំ២០០០ប្រហែលជា៩៧(១៩៩៧)៩៨(១៩៩៨)ដោយសារកូនរបស់បង២០ឆ្នាំជាងហើយ!!
ខ៖ កូនញ៉ុមអាយុ២០ជាងហើយ។
ក៖ ហ្នឹងហើយ។
ខ៖ ញ៉ុមការប្រហែលជាចូល២ឆ្នាំបានមានកូនពីរបីឆ្នាំបានមានកូន។
ក៖ អញ្ចឹងយូរដែរហើយហ្នឹងអញ្ចឹងថាប្រហែល១៩៩៥ទៅអីចឹងដោយសាររៀងជ្រេរមកពីរឆ្នាំ!!
ខ៖ ហ្នឹងហើយ។
ក៖អញ្ចឹងបងសំរាប់ស្វាមីរបស់បងហា៎!!ដូចជាគាត់ជាមនុស្សដូចជាពេលបងរៀបការជាមួយគាត់តើស្រលាញ់គ្នាដោយចិត្តឯងឬក៏មានយាយរៀបចំអោយ ផ្សំផ្គុំអោយ។
ខ៖ ពេលប្តីញ៉ុមហ្នឹងហា៎ពេលគាត់ទៅទិញពោតអើរស្រុកកំពង់ឆ្នាំងហ្នឹងហា៎ទៅលក់ពោតហា៎!!
ក៖ចា៎!!
ខ៖ហាហ្នឹងហើយគាត់លក់ពោត គាត់ទៅទិញពោតនៅហ្នឹង
គាត់ទៅទិញពោតដឹកទាំងឡានៗទៅ គាត់ទៅទៅគាត់ជួបញ៉ុម ញ៉ុមកំពុងលក់បាយ
ញ៉ុមកំពុងលក់បាយជាមួយយាយចិញ្ចឹមញ៉ុមនឹងហា៎!!ដែលញ៉ុមនិយាយហ្នឹងហា៎!!
ក៖ ចា៎!!
ខ៖កំពុងលក់អញ្ចឹងហា៎ ភ្លៅមាន់មួយភ្លៅ១០០០ មាន់ខ្មែរយើងហ្នឹងហា៎មិនមែនដូចមាន់យើង!!
ក៖ ឥឡូវនេះ។

ខះឥឡូវនេះមាន់អ៊ុនគាត់មានស្អីៗដូចយើងនេះស្អីៗអត់ទេមាន់ខ្មែរម៉ងមាន់បើយើងទិញមកមួយ៥០០០ មួយ១០០០០អីទេ មាន់ខ្មែរយើងសុទ្ធៗម៉ងហាំ!!
កះចាំ!!
ខះញ៉ុមទីញមកម្តង១០ យកមកញ៉ុមប្រលាក់ផងញ៉ុមចៀនផងញ៉ុមស្ងរ
ស្ងរគ្រប់មុខអីអញ្ចឹងទៅ ដល់ពេលលក់នៅកំពង់ផែកន្លែងនៅកំពង់ឆ្នាំងហ្នឹងហាំ!!
កះ ចាំ!!
ខះ កំពុងតែលក់ៗអញ្ចឹងហាំ ប្តីញ៉ុមគេមកទិញពោតមកទៅគេចូលហូបបាយ
គេចូលហូបបាយអីចឹងទៅសួរភ្លៅមាន់ហ្នឹងមួយភ្លៅប៉ុន្មាន?ហ៊ីញ៉ុមថា១៥០០ គេថាថ្លៃម្លេះ
១០០០បានហើយ ញ៉ុមថាអត់ទេ ១៥០០ហើយ អញ្ចឹងទៅប្តីញ៉ុមទិញ២ភ្លៅហូប
គាត់ហូបសាច់ច្រើនណាស់គាត់ទិញ២ភ្លៅហើយបាយគាត់ហូបមិនអស់ផងគាត់ទិញ៥០០កាលហ្នឹងហ្ន៎!!
កះ ចាំ!!
ខះ បាយកាលហ្នឹង៥០០ថ្លៃណាស់កាលពីមុនហាំ!!
កះ ហ្នឹងហើយ។
ខះ ៥០០ ១០០០នៅតថ្លៃ ថ្លៃមែនទែនម៉ង ចុះលុយថ្លៃហ្ន៎!!
កះ ចាំ!!
ខះ ហ្នឹងហើយនៅតនៅហ្នឹងនៅតទៀតអត់ចុះទេប៉ុណ្ណឹងហើអីចឹងហាំ!!ហូបបាយហើយហូបអីអញ្ចឹងទៅឃើញថ្ងៃហ្នឹងគាត់ទិញពោតអត់បានអញ្ចឹងគាត់អត់មានផ្ទះដេកហ្ន៎!!ក៏សុំថាហ៊ីមានផ្ទះសំណាក់ណាទេ?សុំមកសួរញ៉ុមថាចៃចៃញ៉ុមនៅហ្នឹងញ៉ុមទឹមមកពីភ្នំពេញអីចឹងញ៉ុមអត់ស្គាល់កន្លែងណាមានផ្ទះសំណាក់នៅហ្នឹងមានផ្ទះសំណាក់តែមានស្រីយួនស្រីយួនច្រើនណាស់ស្រីច្រើនពួកស្រីខូចអញ្ចឹងទៅណាស់!!ញ៉ុមថាណោះមានតែខាងណោះមានតែផ្ទះស្រីខូចហ្ន៎!!ពូឯងទៅសំរាននៅហ្នឹងទៅហើយកាលហ្នឹងគាត់ដាក់លុយមកច្រើនណាស់គាត់ដាក់លុយឡើងមកចង់ប៉ុននេះគាត់ដាក់លុយយកមកទិញពោតហ្ន៎ដឹកឡានទៅវិញហ្ន៎!!ដល់ហើយញ៉ុមប្រាប់ថា ហ៊ីពូឯងទៅដេកផ្ទះសំណាក់ទៅ ប្រាប់គេអោយទៅដេកផ្ទះសំណាក់ហើយ
ថាពូឯងទៅដេកផ្ទះសំណាក់ហ្នឹងហ្នឹងតែស្រីយួនយកលុយអស់ហើយ។
កះ យកលុយមួយចង់ហ្នឹងហោ?
ខះ ហ្នឹងហើយញ៉ុមថាដឹងតែស្រីយួនយកអស់ហើយដល់ពេលហើយអីចឹងទៅញ៉ុមក៏អានិតគាត់ ឥឡូវពូឯងអើរសុំផ្ទះយាយញ៉ុមនៅទៅញ៉ុមអត់មាននិយាយថាអោយនៅខ្លួនឯងចិត្តខ្លួនឯងទេណាស់អោយសុំយាយទៅអានិតគាត់ លុយច្រើនណាស់ខ្លាចគេយកអីអិចឹងហាំ!!

ដល់ពេលហើយញ៉ុមប្រាប់យាយយាយណោះពូនោះគាត់សុំផ្ទះដេកមួយយប់ហ្នំព្រលឹមឡើង
គាត់ ទិញពោតទៅវិញហើយគាត់ម៉ូយបាយយើងដែរតើគាត់មកហូបបាយយើងពេលព្រឹក
មិញដែរញ៉ុមនិយាយអីចឹងហាំ!!ហើយយាយញ៉ុមនិយាយថាអើរអានិតអើរអោយវាដេកដេក
ទៅ ក៏ហៅប្ដីញ៉ុមអោយទៅដេកទៅ ដេកនៅបានមួយយប់ព្រលឹមឡើងគាត់ទិញពោតបាន
អត់បានមួយយប់ទៀតអញ្ចឹងទៅដល់ល្ងាច ប្រាប់ពោតពោត កម្ម៉ង់ដូចថាគាត់យក៤
៥ទូកអីចឹងទៅណាស់ដឹកដាក់មួយឡានយកទៅភ្នំពេញអញ្ចឹងទៅណាស់ !!
កៈ ហ៊ឺៗ!!
ខៈ កម្ម៉ង់គេទៅបានទៅទៅបានបាន២ថ្ងៃបានបានឡើងទៅភ្នំពេញ នៅដេកបាន២យប់។
កៈ អីយ៉ាស់ចាប់ផ្ដើមលួចស្រលាញ់គេតិចៗ!!
ខៈ ហ្នឹងហើយ!!អត់ទេញ៉ុមអត់ដែលស្រលាញ់ទេ!!
កៈ អត់ទេប្ដីបង។
ខៈ ហ្នឹងហើយប្ដីញ៉ុម!
កៈ គាត់មើលណោស!!!
ខៈហ្នឹងហើយ!!ដល់ពេលហើយគាត់ទិញអីអញ្ចឹងទៅគាត់បានអញ្ចឹងទៅគាត់ថាហ៊ឺអ៊ំអើយញ៉ុម
អរគុណហើយគាត់ចេះតែចុះឡើងចុះឡើងទិញទៅណាស់គាត់គាត់ទៅមកទៅមកគាត់លក់
ពោតហ្នំ លក់ផ្សារដើមគរហ្នំ!!គាត់មកដើរទិញគ្រប់កន្លែងហាំគាត់ចេះតែមកដើរទិញលក់
ទិញលក់អញ្ចឹងទៅ ដល់ពេលគាត់ថា ញ៉ុមសួរញ៉ុមថាថីយាយហ្នឹងថាហ៊ឺយាយចិញ្ចឹម
យាយនៅចិញ្ចឹមអីចឹងទៅណាស់!!
កៈ ចាំ!!
ខៈ ហើយគាត់ស្រលាញ់ញ៉ុមគាត់ស្រលាញ់ញ៉ុមអត់ស្រលាញ់គាត់ទេហៅគាត់ថាគាត់
ក្មេកញ៉ុមថា(គាត់អង្គុយពាក់វ៉ែនតា)គាត់ថាចូលដណ្ដឹងញ៉ុមទៅគាត់ស្រលាញ់ញ៉ុមអញ្ចឹងទៅ
ណាស់ ឃើញញ៉ុមស្លូតអីអញ្ចឹងទៅណាស់ដល់ហើយញ៉ុមនិយាយថាញ៉ុមអត់យកទេប្រាប់ប្ដី
ញ៉ុមថាញ៉ុមអត់យកទេ យាយការខ្លួនឯងការអោយគេញ៉ុមស្ដីអោយយាយចិញ្ចឹមញ៉ុមហ្នឹង
អើយយាយឯងរកកូនណាការការទៅញ៉ុមអត់ស្រលាញ់ទេញ៉ុមអត់ទាន់ចេះស្រលាញ់ប្រុស
ចេះស្រលាញ់អីណាស់!!
កៈ ចាំ!!ខៈអោយតែឮអាណាស្រលាញ់ញ៉ុមជេរហើយ។
កៈ តែពេលហ្នឹងប៉ុន្មានឆ្នាំបានរៀបការអាយុប៉ុន្មាន?
ខៈ អាយុប៉ុន្មាន ១៨ ១៩។
កៈ ហ្នូទឹមតែប៉ុណ្ណឹង។

ខ៖ ហ្នឹង១៨ ១៩តើ!!ញ៉ុមថាហ្នឹងហើយញ៉ុមអត់ចេះស្រលាញ់ទេញ៉ុមអត់យកទេប្តីហ្ន៎!!ញ៉ុម និយាយអញ្ចឹង យាយចេះតែបង្ខំអោយការការ១៨១៩ហ្នឹងការហើយបានប្តីញ៉ុមហ្នឹងស្រលាញ់ពួកម៉ាក់ញ៉ុមទៀត ពួកម៉ាក់ញ៉ុមហ្នឹងហួស!!គេចេះតែស្រលាញ់ប្តីញ៉ុមហើយ ស្រលាញ់ញ៉ុមបញ្ចេះប្តីញ៉ុមអោយស្រលាញ់ពួកម៉ាក់ញ៉ុមទៅ ញ៉ុមថាអញ្ចឹងហា៎!!

ក៖ ចា៎!!

ខ៖ កុំយកញ៉ុមអីយកពួកម៉ាក់ញ៉ុមទៅហើយប្តីញ៉ុមអត់មានស្រលាញ់ទេគាត់ស្រលាញ់តែញ៉ុម។

ក៖ ចា៎!!

ខ៖ ពួកម៉ាក់ញ៉ុមស្អាតៗណាស់ ញ៉ុមថាអញ្ចឹងហា៎ នោះពួកម៉ាក់ញ៉ុមស្អាតៗណាស់។

ក៖ ចា៎!!

ខ៖ ពូឯងស្រលាញ់ទៅ ពូឯងទៅ បញ្ចេះប្តីខ្លួនឯងហ្នឹងអោយស្រលាញ់ពួកម៉ាក់ខ្លួនឯងទៅ !

ក៖ ហ៊ឺៗ!!

ខ៖ អត់អោយគាត់មកដណ្តឹងញ៉ុមទេ!!អញ្ចឹងហា៎!!

ក៖ ចា៎!!

ខ៖ ប្តីញ៉ុមថាអត់ទេដណ្តឹងញ៉ុម  គាត់មកដណ្តឹងញ៉ុមទៅ។

ក៖ ក៏បានរៀបការអញ្ចឹងទៅ?

ខ៖ ចា៎ក៏បានការហ្នឹងអញ្ចឹងសួរយាយសួរអីអញ្ចឹងទៅសួរថាប៉ុន្មានអញ្ចឹងទៅ អស់មួយដំឡឹងហ្នឹងកាលហ្នឹង មួយដំឡឹងលុយថ្លៃណាស់ កាលជំនាន់។

ក៖ កាលម៉ាជំនាន់មាស!!

ខ៖ ហ្នឹងហើយមួយដំឡឹងៗហា៎!!ដណ្តឹងការ អីទៅការហើយអីហើយបានញ៉ុមមកនៅភ្នំពេញនេះប្តីញ៉ុមយកឡើងមកនៅភ្នំពេញវិញ។

ក៖ ក៏បែកពីយាយនោះមកទៅ។

ខ៖ ហ្នឹងហើយ បែកពីយាយ យាយថាគាត់យំអោបអីអញ្ចឹងទៅណាស់។

ក៖ ពេលនៅវ៉ែចង់ងាប់!

ខ៖ ហ្នឹងហើយដល់ពេលធ្លាប់នៅជាមួយគាត់គាត់ចេះតែយំនឹកអីអឺចឹងទៅណាស់អានិតយើងអីអញ្ចឹងទៅណាស់!!

ក៖ ហ៊ឺៗ!!

ខ៖ អោបយំអីអញ្ចឹងទៅឡើងមកភ្នំពេញ។

កៈ ការហើយបានប៉ុន្មានថ្ងៃបានឡើងមកភ្នំពេញវិញ?

ខៈ ការហើយប្រហែលជាបាន២ ៣ថ្ងៃហ្នឹងឡើងមកហើយ។

កៈ ហ្អូ!!

ខៈ ៣ ៤ថ្ងៃបានឡើងមកសុំគាត់ឡើងមកភ្នំពេញប្ដីថានាំយកមកភ្នំពេញហើយយកទៅនៅណោះ ហើយយាយគាត់លក់ផ្ទះលក់អីមកនៅភ្នំពេញដែរមក។

កៈ ហ្នឹងក៏ដាច់មុខរបរនៅណោះទៅ!!

ខៈ ហ្នឹងក៏ដាច់មុខរបរទៅ។

កៈ ចុះបងសំរាប់ពេលបងរៀបការហើយបងមានកូនប្រុសស្រីប៉ុន្មាននាក់ដែរ?

ខៈ កូនញ៉ុមប្រុស៤មើល!!ទាំងអស់ត្រូវប្រុស៥ស្រី១។

កៈ ចាំ ស្រីតែមួយទេ?

ខៈ ចាំ!!ហ្នឹង៦ទាំងអាហ្នឹង តែស្លាប់អស់មួយនៅសល់តែ៥ទេ រាល់ថ្ងៃ។

កៈ កូនស្លាប់មួយថីបានស្លាប់បង?

ខៈ វាកើតស្អីគេគ្រុនឈាម។

កៈហ្អូ!!

ខៈ៣ថ្ងៃ។

កៈ ជំនាន់ណាពេលហ្នឹង?

ខៈ ទឹមយើងឥឡូវៗហ្នឹងដែរប្រហែលជាប៉ុន្មានឆ្នាំយើងហ្នឹង។

កៈ ម៉េចអោយដល់ស្លាប់បងសម័យឥឡូវពេទ្យមើលជាសោះហ្នឹងបើថាជំនាន់ហ្នឹងទៅបានថានេះដល់វាញ៉ុមប្រហែសពេកអីចឹងហើយ!!

កៈ អត់ដឹងហោ?

ខៈ ក្ដៅត្រជាក់ក្ដៅត្រជាក់ កូនត្រជាក់ក្ដៅត្រជាក់ក្ដៅរហូត។

កៈ អូយឈឺចិត្តងាប់ហើយបងដល់ពេលអ៊ិចឹង។

ខៈ វាចេះដើរហើយហ្នឹងចេះដើរតេតាសតេតាសហើយហ្នឹង។

កៈ អូយ!!

ខៈ ហើយថ្លោះជាងអានេះសរជាងអានេះទៅទៀត។

កៈ អូយងាប់ហើយអានិតងាប់ហើយលោកអើយលោក។

ខៈ តេតាសតេតាសស្អាតណាស់អាហ្នឹងនោះ។

កៈ ប្រហែលប៉ុន្មានឆ្នាំទៅបង?

ខ៖ ប្រហែលជាមើលអាបង ប្រហែលអាបន្ទាប់អានេះប្រហែលជាអាមួយស្លាប់ហ្នឹង !អាមួយនោះ១៣ហើយ១៣ឆ្នាំហើយអាបងវាហ្នឹង បែបចូលបួនដប់ឆ្នាំហើយ២០ឆ្នាំហើយ។

ក៖ ហើយបងឯងបានកូនល្អៗម្លេះនេះ!!

ខ៖ ហ្នឹងអាមួយស្លាប់រូបថតវានៅតើ!!

ក៖ សុទ្ធតែនិយាយទៅ និយាយទៅសុទ្ធតែអ៊ីចឹងទាំងអស់ម៉ងបងហេ?

ខ៖ ហ្នឹងហើយ កូនញ៉ុមអ៊ីចឹងទាំងអស់ កើតមកអ៊ីចឹងទាំងអស់ថ្លោះៗអ៊ីចឹង !!បើល្ងាចអាបងវារាំហ្ន៎តាមប៉ុស្តិ៍ហ្ន៎ !!គេអោយមួយខែ៥០០ ធ្វើអត់ទៅធ្វើទៀត!!

ក៖ នៅប៉ុស្តិ៍អីគេបង?

ខ៖ វារាំជាមួយអីណូអី អ៊ីណូហៅវាឡើងរាំអ៊ីចឹងទៅ រាំបាន១៥រៀល២០រៀលអីអញ្ចឹងទៅ។

ក៖ មែន កូនបងឯងប្រុសពេញលក្ខណៈតើហី?

ខ៖ កូនញ៉ុមប្រុសតើ!!

ក៖ ហ្ន៎ស្មានតែនេះ!!

ខ៖ អត់ទេមិនមែនខ្ទើយទេ អាហ្នឹងខ្ពស់ស្រលះស្អាតម៉ងហា៎!!ខ្មៅម៉ងហា៎!!

ក៖ ចាំមើលបានកូនប្រសារតារាម៉ងហា៎!!

ខ៖ គេថាអូយម៉ែអើរស្រីៗស្រលាញ់ញ៉ុមច្រើនណាស់!!

ក៖ អូខេអ៊ីចឹងបងប្រាប់ឈ្មោះកូនទាំងអស់មើលកូនឈ្មោះអីគេខ្លះ?

ខ៖ កូនញ៉ុមហេ?

ក៖ ពីបងគេទាំងស្លាប់ដែរអ៊ីចឹងហា៎ ដល់អាមួយទូចនេះ?

ខ៖ កូនញ៉ុមអាបងគេឈ្មោះចំណាប់។ក៖ចា៎!!ខ៖ ហ្វៃយ ចំណាប់ កូនស្រីញ៉ុម ហ្វៃយ ស្រីខូចទី២ហា៎!!

ក៖ ស្រីតែមួយហ្នឹង?

ខ៖ ហ្នឹងហើយ ស្រីតែមួយហ្នឹង ទី២។

ក៖ចា៎!!

ខ៖អាទីមួយហ្វៃយចំណាប់អាទី២ហ្វៃយ ស្រីខូច។

ក៖ ទី៣?

ខ៖ ទី៣ ហ្វៃយ ចំណាន ទី៤ទី៤ឈ្មោះ សុខហ្វៃរ។

ក៖ចា៎ អាមួយអាអូនស្លាប់នឹងហេ?

ខ៖ ហ្នឹងហើយ ឈ្មោះសុខហ្វៃរ ហើយដល់ពេលទី៥ឈ្មោះ សុវណ្ណារិទ្ធ។

ក៖ចា៎!!

ខ៖ ឈ្មោះសុវណ្ណារិទ្ធអាសុវណ្ណារិទ្ធទៅណាបាត់ហើយខូចដល់ហើយប៉ុននេះហើយ ១៣ហើយ។
ក៖ ហ្វ៎ ហើយដល់ពេលអានេះ?
ខ៖ អានេះ ដល់ពេលអានេះ ទី៦នេះ ហ្វយ កក្កដា !! កក្កដានេះ។
ក៖ ហៅឈ្មោះគេសើច។ហើយមួយៗបងប្អូនស្រលាញ់ប៉ុណ្ណាទៅបើអញ្ចឹងនេះ??
ខ៖ អាបងមួយវារាំហ្នឹងមកម្តងៗថើបវាជិតងាប់ជិតរស់។
ក៖ តាមពិតបំរុងឈប់យកកូនហើយមែនទេបង?
ខ៖ អត់ទេ ញ៉ុមបំរុងឈប់ប៉ុន្តែអាមួយនោះអាមួយដែលថាម៉ែវាស្លាប់បងស្រីញ៉ុមនោះ(គាត់ប្រាប់មុខកូនប្រុសបងស្រីគាត់) !! ញ៉ុមថាឈប់យកហើយវាដូចថាវាមកសុំនៅមកសុំនៅពេលញ៉ុមនៅភ្នំពេញហាំ!!លក់ផ្ទះមកនៅនេះហ្វ៎!!
ក៖ហ៊ឺ!!
ខ៖ យល់សប្តិឃើញថាមកសុំនៅថាហ៊ឺថាញ៉ុមមកហ្នឹងស្រីទេមិនមែនប្រុសទេ។
ក៖ ចាញ់បោកយល់សប្តិ!!
ខ៖ ហ្នឹងហើយហ្នឹងហើយថាអញ្ចេកសុំនៅទៅកុំយកញ៉ុមចេញអីញ៉ុមសុំអង្វរ ញ៉ុមមកស្រីទេហើយសក់ក្បាលឡើងក្រញាញ់រួញឡើងកាតុលកាតុលសុំមកនៅកូនស្រីហាំ!!ថាកុំយកចេញសុំអង្វរទុកទុកទៅញ៉ុមរកយកចេញពីរបីសារញ៉ុមដើររកខ្ចីលុយគេទំលាក់ពីរបីដងហើយនៅអត់បាន នៅតែអត់បានទៅអត់បានទៅឡើងរហូតបាន៣៩ខែហាំគិតមកឥឡូវទុកមករហូតរហូតទាល់តែបានគ្នាហ្នឹង។
ក៖ បានមួយកំថ្លង់ៗអ៊ីចឹងទៅ!!
ខ៖ កុំអីយកចេញបាត់មិនដឹងទៅដល់ណាទេ។
ក៖ អ៊ីចឹងបងឥឡូវប្តីបងគាត់រកស៊ីអីគេដែរ?
ខ៖ គាត់រត់ឌុប។
ក៖ រត់ឌុបហោ!!មួយថ្ងៃៗបានច្រើនទេបង?
ខ៖ ហ៊ឺឥឡូវសំបូរអាកង់បីហើយឡាន ឡានយើងឥឡូវសុទ្ធតែជិះ២០០០ ៤០០០ ៥០០០យើងហ្នឹង!!
ក៖ អ៊ីចឹងក៏អត់សូវ!!
ខ៖ អ៊ីចឹងឥឡូវរកអត់សូវបានដូចមុនទេមុនបាន៤០០០០៥០០០រត់មួយថ្ងៃវាស់ល្ងាចបាន ១០០០០០ក៏មានដែរ។
ក៖ ហ្វ!!បានច្រើន។

ខ៖ តែឥឡូវអត់បានទៅរត់ទេ!!ហើយណាមួយអត់មានម៉ូតូ!!
ក៖ ហើយឥឡូវធ្វើអីគេវិញទៅ?
ខ៖ នៅតែផ្ទះ នៅផ្ទះសិនទៅ សុំលុយកូនចាយ។
ក៖ កូនចិញ្ចឹមវិញម្តង។
ខ៖ សុំលុយអាមួយរាំហ្នឹងទៅ សុំលុយមីស្រីនៅឈូកកំពតហ្នុំ!!ក៖ចាំ!!ខ៖សុំលុយវាចាយ
វាធ្វើការចេះតែសុំវាបានចាយអីចឹងទៅណាស់!!
ក៖ ចាំ!! កូនស្រីហ្នឹងរៀបការនៅ?
ខ៖ នៅនៅទាំងអស់។
ក៖ អត់ទាន់មានអ្នកណាគេការអីមួយទេ?
ខ៖ នៅទាំងអស់។
ក៖ ហើយម៉េចអោយកូនទៅឆ្ងាយម្លេះបង?
ខ៖ វាទៅនៅជាមួយមីងវា វាទៅជួយលក់គេ ហ្នឹងហើយ។
ក៖ មិនព្រមបង្កើតនៅជាមួយម៉ែឯងទេបានជួយគ្នា។
ខ៖ យើងមិនទាន់មានលុយហើយណាមួយណោះវិញ ញុំមចង់ថាខ្ចីលុយអង្គការ
ធ្វើបើកមុខរបរអីរកដែរតែនៅណាមួយនៅនេះអត់សូវមានអីដែលលក់ដាច់អីផង
មិនទាន់មាន។
ក៖ អូខេ អញ្ចឹងសំរាប់ជីវិតរបស់បង ដោយសារប្រទេសយើងមានជួបសង្គ្រាមមែនទេបង?
ខ៖ ហ្នឹងហើយ។
ក៖ ប៉ុល ពត លន់ នល់អីអីចឹង!!
ខ៖ ហ្នឹងហើយ។
ក៖ បងធ្លាប់ឮអីគេខ្លះពីជីវិតពីពេលវេលាហ្នឹងទៅ ដូចបានស្គាល់អីគេខ្លះពីមួយហ្នឹង
ឮតពីចាស់ៗមកហា!!
ខ៖ ពីថាម៉េច?
ក៖ ពីរបបសង្គ្រាមហា ថាតើនៅក្នុងសង្គ្រាមប៉ុល ពតហ្នឹងវាម៉េចខ្លះអីចឹងទៅណាស់?
ខ៖ អត់!!
ក៖ ដែលឮពីប្រវត្តិសង្គ្រាមអីហ្នឹងអត់?
ខ៖អត់ ។
ក៖ តែអត់មានអ្នកណាគេនិយាយប្រាប់អីវ៉ាន់ណាថាប៉ុលពតរងទុក្ខវេទនាយ៉ាងម៉េចអិចឹងហាំ?
ខ៖ ធ្លាប់តែមើលទូរទស្សន៍។

កៈ ហ្នឹងហើយ បងអាចដឹងអាចនិយាយពីជំនាន់ហ្នឹង។
ខៈ បើខែ ខែដែលស្អីគេទេ»!!បុណ្យស្អីគេ!!
កៈ ៧មករាហោ?
ខៈ ហ្នឹងហើយ៧មករាគេបើកទូរទស្សន៍បើកអីមើលហ្នឹង!!
កៈ ចាំ!!
ខៈឃើញដែរតើឃើញ អូយសម័យអាពតអីចឹងណោះ គេវៃមនុស្ស គេវៃមនុស្សទំលាក់!!
កៈ ហើយម៉ែមានដែលប្រាប់អីអត់?ថាជីវិតរបស់គាត់ម៉េច?
ខៈ ម៉ែ បើសិនតែម៉ែញ៉ុមអត់ដែលប្រាប់ទេ បើសិនជាម៉ែក្មេកញ៉ុមបានប្រាប់។
កៈ ម៉ែក្មេកប្រាប់ថាម៉េច?
ខៈ គាត់ថាសម័យអាពតខ្លះកូនគាត់ហូបពោតឆៅពោតអីហើយអត់មានអីហូបដើររើសនេះរើសនោះហូបសម័យអាពតហើយញ៉ុមថាអូបើញ៉ុមកើតទាន់សម័យអាពតប្រហែលវេទនាដែរហើយអញ្ចឹងទៅនៅនឹកឃើញក្នុងចិត្តហាំ!!នឹកឃើញទូរទស្សន៍គេបញ្ចាំងអញ្ចឹងហាំថាអូគេវៃមនុស្សទំលាក់ភូសភូស ជីករណ្ដៅដាក់គរជើងគ្នាអីចឹងទៅណាស់ ។
កៈហ៊ី!!
ខៈញ៉ុមស្រម៉ៃថាញ៉ុមបើដូចសម័យអាពត ដូចគេដូចឯងអញ្ចឹងងាប់ហើយ។
កៈ មែនហ្នឹងបង!!
ខៈ យើងកើតអត់ទាន់នឹកឃើញអញ្ចឹងហាំ!!!
កៈ ចាំ!!
ខៈ វេទនាគេប្រើ!!ឃើញអញ្ចឹងបើថាកើតសម័យអាពតមិនដឹងថាវេទនាប៉ុណ្ណាទេណាស់!!ចេះកើតហើយ ដូចគាំតអីហ្នឹង!!
កៈ ញ៉ុមកើតអត់ទាន់ទេ ក្មេងជំនាន់ក្រោយ។ចាំអញ្ចឹងបងម្ដាយបងអត់ដែលប្រាប់ពីជីវិតមួយហ្នឹងនៅពេលនៅពីក្មេងហ្នឹង អត់ដែលប្រាប់បងឯងទេចុះ?
ខៈ អត់!!!
កៈ ទាំងឪ តែពេលជំនាន់ប៉ុល ពតហ្នឹងឪវ៉ាន់ម៉ែវ៉ាន់នៅវៀតណាមណោះទេហី?
ខៈ ហ្នឹងហើយ។
កៈ ហ្ហ៎ ហ្នឹងហើយចឹអញ្ចឹងបានផុតពីជំនាន់ហ្នឹងហ្ហ៎!!
ខៈ ហ្នឹងហើយ ជំនាន់ហ្នឹង តែអត់ដែលនិយាយប្រាប់យើងពីជំនាន់ហ្នឹងផង។
កៈ ហេងហើយអីចឹងបងឯង។

ខ៖ បើម៉ែក្មេកញ៉ុម បានគាត់ដែលនិយាយប្រាប់ថាគាត់សម័យអាពតគាត់ធ្លាប់រស់នៅវេទនា ពួកហ្អែងហាំបើសម័យអាពតងាប់អស់ហើយមិនស្រួលហ្ន៎!! គ្មានបាយគ្មានទឹកស៊ីទេ ចេះតែជេរពួកក្មេងៗហ្នឹងហាំ!!!

ក៖ហ៊ឹៗ!!

ខ៖គេដាំបាយទាន់មិនទាន់ស៊ីមិនទាន់ហុចទឹកបបរអីអញ្ចឹងទៅណាស់។

ក៖ ចាំ ហ្នឹងហើយ អ៊ីចឹងបងសំរាប់កូនរបស់បងហាំ ទាំងប៉ុន្មាននាក់ហ្នឹងបងមានអោយគាត់ទៅរៀនទាំងអស់គ្នាទេ?

ខ៖ កូនញ៉ុមបានទៅរៀនទាំងអស់ហ្នឹង។

ក៖ ចាំ!!!ចេះបានរៀនចប់ទេ?

ខ៖ បានតែអាទីបីទេដែលបានរៀនដល់ថ្នាក់ទី១០ជាង ថ្នាក់ទី១១។

ក៖ ចាំ ចុះក្រៅពីហ្នឹងវិញ?

ខ៖ បើក្រៅពីហ្នឹងវិញថ្នាក់តិចៗណាស់។

ក៖ ពេលហ្នឹងបងឯងអោយគាត់ឈប់ឬក៏ម៉េចដែរ ឈប់ខ្លួនឯង?

ខ៖ ហ៊ឹឈប់ខ្លួនឯង។

ក៖ រៀនអត់ចេះឬក៏ម៉េច?

ខ៖ អាបងគេបង្អស់ហ្នឹងអោយទៅរៀនហ្នឹង ទៅរៀនរហូតដល់ពេលហើយប្រាប់វា ថាអញ្ចេកកូនកូនឯងទៅរៀនទៅវាទៅរៀនរាល់ថ្ងៃ ដល់ពេលកន្លះខែក្រោយមក សួរវាថាអញ្ចេក គ្រូតេមកថាចំកូនញ៉ុមទៅរៀនរាល់ថ្ងៃ វារៀនថ្នាក់ទី៧ អាបងគេហាំ!!

ក៖ហ៊ឹៗ!!

ខ៖ឡើងសាលាលើហើយវាបែកថ្នាក់ហាំ!!ចំទៅរៀនរាល់ថ្ងៃម៉េចគ្រូតេមកអញ្ចឹង!! ហ៊ឹកូនសិស្សហ្នឹងខានរៀនមួយខែហើយ ថាហេមួយខែអី!!កូនញ៉ុមទៅរៀនរាល់ថ្ងៃ ដល់ពេលសួរវាវាថាវាអត់បានទៅរៀនផងវាបានតែពាក់ខោអាវអញ្ចឹងៗទៅ។

ក៖ បោកសោះ។

ខ៖ ហ្នឹងហើយវាដើរលេងដល់ល្ងាចម៉ោង៥ដឹងតែចូលផ្ទះហើយដឹងថាហ៊ឹកូនអញមកពី រៀនហើយដឹងថាអញ្ចឹងហ្ន៎!! ដឹងតែចូលផ្ទះហើយ ហ្ន៎ទៅរៀនអញ្ចឹងទៅដឹងតែចូលផ្ទះរាល់ថ្ងៃ ដល់ពេលមួយខែពេញគ្រូថាអត់រៀនទេ!! ដល់ពេលសួរវាទៅ ញ៉ុមអត់រ៉ែអត់អីទេ ដល់ពេលសួរវាទៅ ម៉េចអត់ទៅរៀនអញ្ចឹង គ្រូគេថាអោយវាចូលរៀនចូលអីវិញអ៊ីចឹងទៅ ហ៊ឹវាថាវារៀនអត់ចូល។

ក៖ កាលហ្នឹងរៀនទី៧ហោ?

ខះ ហ្នឹងហើយរៀនអត់ចូលឈឺក្បាលណាស់!!
កះ ដល់អញ្ចឹងឥឡូវទៅចាប់ជំនាញអ្នករាំវិញ?
ខះ ហ្នឹងហើយ!! អត់ទេ អាហ្នឹងបងគេបង្អស់។
កះហ្ហ៎!!
ខះ បន្ទាប់មកមីទីពីរហ្នឹងក៏អញ្ចឹងដែរ មីស្រីហ្នឹងអោយរៀនរៀន ក៏រៀនអត់សូវចេះដែរ បានតែថ្នាក់ទី៥ទីអីហ្នឹងឈប់ទៅ អោយ រៀនទៀតបង្ខំអោយកូនរៀនទៀតកូនវាអត់រៀនទេឈប់ទៅហើយអាថ្នាក់ទី៣ទៀត អាទី៣ អាទី៣ម្ដងញ៉ុមថាអាទី៣វាឈប់តាំងថ្នាក់ទី៤ ហើយរៀនដល់ថ្នាក់ទី៤ហើយម៉ែញ៉ុមឈប់ហើយណាស់ហ៊ីកូនឯងឈប់អីចឹងហើយអត់ចេះអក្សរទេ កូនឯងខំរៀនទៅអូយញ៉ុមគ្មានអីជិះទេម៉ែឆ្ងាយពេកផ្ទះនៅឆ្ងាយពេកខ្ញុំគ្មានទេខ្ញុំខ្ជិលញ៉ុមឈប់រៀនហើយ ទៅនៅជាមួយអង្គការយើងនៅច្បាអំពៅហ្នឹងញ៉ុមទៅរាំញ៉ុមទៅរាំហើយហ៊ីហ្អែងទៅរៀនរាំគេមានសាលាអត់ មានតើម៉ែសាលាគេរៀនផងគេរាំផង ចឹងហ្អែងទៅរៀនរាំទៅបើហ្អែងអត់រៀនអញ្ចឹងអញមិនដឹងទេហ្អែងអត់ចេះខ្លួនឯងទេ ដល់ពេលវាទៅសាលាច្បារអំពៅវាបានរាំវាបានអីជាមួយគេហើយរៀនផង ហើយបានរៀនអង់គ្លេសទៀតហ្ហ៎!!!
កះ ហ្នឹងហើយ។
ខះ ហ្នឹងហើយ អង់គ្លេសផងអីផងទៅអង្គការគេថាហ៊ីដាក់វាចូលសាលារៀនទៅ ច្បារអំពៅយើងហ្នឹងអាសាលារៀនច្បារអំពៅហ្នឹង អាគេហៅថាអាកន្លែងវត្តស្អីគេនោះ!!!
កះ ចាំ!! វត្តនិរូត។
ខះ ហ្នឹងហើយគេថាហ៊ីឥឡូវហ្នឹងកូនហ្នឹងយកស្អីៗមកគេអោយចូលរៀនហើយណាស់ គេអោយចូលរៀន ឥឡូវដល់បានវារៀនហ្នឹងបានឡើងថ្នាក់ទី១០ ទី១១ហើយហ្នឹង។
កះ ក៏បានរៀនទៅ។
ខះ បានរៀនដល់ឥឡូវទៅ។
កះ ហ្នឹងបើនៅជាមួយមីងប្រហែលជាខ្ជិល។
ខះ ហ្នឹងហើយ។
កះ ថានៅជាមួយម៉ែហ្ហ៎!!
ខះ ហ្នឹង ដល់ពេលទៅវាឈប់រៀនជាមួយអាសាលារៀនរដ្ឋហើយយើងនេះហ្ហ៎!!ទៅនៅជាមួយអង្គការគេហៅខាងគេ ខាងក្រុមគេរាំហ្នឹងហាំ វាបានរៀនបានអីដល់ឥឡូវហ្នឹង ឥឡូវនៅតែអីហ្នឹង ល្ងាចទៅជូនកាលវាមកលេងញ៉ុមមួយសារៗ ល្ងាចថ្ងៃអាទិត្យថ្ងៃសៅរ៍អីហ្នឹង។
កះ រាំរបាំរាំអីហ្នឹងមែនទេបង?

ខ៖ អត់ទេវារាំក្បាច់ឌីជេ ឌីអីហ្នឹង។
ក៖ រាំក្បាច់តាមឌីជេអីហ្នឹងមែន?
ខ៖ ហ្នឹងហើយរាំកាយវិការអីហ្នឹងអីណ្វាដូចថាអីណ្វាកំពុងច្រៀងអញ្ចឹងគេរាំបទឡូកតាមក្រោយគេអីអញ្ចឹងទៅ ដូចថាធ្វើកាយវិការតាមក្រោយគេអ្នកចំរៀងអីអញ្ចឹងទៅណាស់!!
ក៖ ហ្នឹងហើយហ្នឹងហើយ ហ៊ុឡូយណាស់អីចឹង!!
ខ៖ ហ្នឹងហើយ!!តែវាខ្ពស់ស្អាតណាស់!!វាខ្ពស់ហើយសក់ក្បាលវាកាត់ស្អាតណាស់។
ក៖ ប៉ុន្មានឆ្នាំហើយឥឡូវ?
ខ៖ ឥឡូវអាហ្នឹងប្រហែលជា១៨ហើយ ១៧ ១៨ហើយ។
ក៖ អញ្ចឹងបងបងគិតថាការសិក្សាម៉េចដែរបានជាបងអោយកូនទៅរៀនអញ្ចឹងហាំ សំខាន់ម៉េចដែរបានអោយកូនទៅរៀន?
ខ៖ វាវាថាវាចង់ចេះខ្លួនវាថាហ្បែងទៅរៀនទៅ ថាទៅថ្ងៃអនាគតទៅក្រែលលោះវាចេះ ដល់ពេលឥឡូវគ្រូហ្នឹងគេអោយវាហ្នឹងទៅនេះ រៀនចេះរៀនអីទៅគេអោយទៅអង់គ្លេស!! ធ្វើប៉ះស្តោរធ្វើអីអីចឹងទៅណាស់ គេរកយកទៅអង់គ្លេសខែ៩ហ្នឹងហ៎!!ដល់ពេលទៅវារាំរាំៗ វាភ្លៀតដៃវាដូលាតហ្ន៎!!វាដូលាត៣ត្រលប់ហ្ន៎!! យើងយើងធ្វើដូលាតអត់ដូចវាទេណាស់ វាវាឈរអីចឹងហាំ វាដូលាតបង្វិលខ្លួន បង្វិលមួយត្រលប់អញ្ចឹងទៅណាស់មួយត្រលប់មួយត្រលប់ទៀតអញ្ចឹងទៅណាស់!!វាផ្លៀតទៅវាយកដៃច្រត់អញ្ចេះហ្ន៎!!វាច្រត់ទៅវាបាក់ដៃវា បាក់ដៃបានប្រហែលជាខ្វង់មួយខែអញ្ចឹងហើយនេះតាំងពីខែពីរទៅវាបាក់ដៃទៅអស់មួយខែ ហ្នឹងឥឡូវវារាងប៉ោងបន្តិចហើយ មើលវាជាហើយតែវានៅវារាងប៉ោងដៃអញ្ចេក។
ក៖ហ៊ឺ!!
ខ៖ឥឡូវវាឈប់រៀនវាឈប់រៀនបានមួយខែហើយ!!ញ៉ុមថាដេញវាចូលរៀនវិញញ៉ុមថាកូនឯងចូល វិញទៅណាស់កុំឈប់កុំអីណាកូននៅរៀនតទៅណាស់វាថាហ៊ឺម៉ែអើយញ៉ុមសុំច្បាប់គ្រូមួយខែ ព្រោះញ៉ុមបាក់ដៃអញ្ចឹងទៅណាស់!!
ក៖ហ៊ឺៗ!!
ខ៖ ខាងអីណ្វាខាងអ្នកចំរៀងអីគេជួយ៩ ១០រៀលគេអោយអញ្ចឹងទៅណាស់!!
ក៖ហ៊ឺៗ!!
ខ៖ មានអីយកទៅពេទ្យជប៉ុនគេមើលគេពិនិត្យមើលដៃវាគេថាបើសិនជាវះដាក់ឆ្អឹងដាក់អីអញ្ចឹងណាស់ដាក់ដែកអញ្ចឹង ៩០០ ថតមើលបាក់៣កំនាត់ហ្ន៎!!
ក៖អូយ!!

ខ៖ ហ្នឹងហើយ គេជួយគេចេញលុយអោយអញ្ចឹងទៅណាស់ ហើយញ៉ុមថាអត់ទេ គ្រូខ្មែរ ញ៉ុមអត់អោយវាទៅវ:ទេ អោយវាទៅគ្រូខ្មែរ ព្រោះវាជិតចេញទៅក្រៅអញ្ចឹងហាំ!! ខ្លាចវាអត់ជា ចាំដល់ពេលយកវាទៅមើលគ្រូខ្មែរនៅអាកន្លែងស្ថានីយ៍បូមទឹករបស់ជប៉ុននោះ ទៅមើលគ្រូខ្មែរទៅ ឥឡូវវាបានគ្រូខ្មែរហ្នឹងផ្លុំៗ រឺតយកថ្នាំគាត់អីមិនដឹងទេ!! ទៅជាទៅ តែជាវាអត់ឈឺហើយតែរាងប៉ោងឆ្អឹងកន្លែងនេះបន្តិច កន្លែងនេះរាងប៉ោងអញ្ចេក។

ក៖ អញ្ចឹងអនាគតគេគេទៅស្រុកគេហើយណោះ?

ខ៖ អត់ទេប្រហែលអត់បានទៅទេ ដល់ពេលអញ្ចឹងទៅគេនឹកឃើញថាជិតទៅ ក្រែងលោរដៃវាអត់ទាន់ជា តែឥឡូវវាធ្វើប៉ះស្ព័រអីហើយអស់ហើយប៉ះស្ព័រហ្នឹងគេហៅអោយវាទៅយកហើយ!!

ក៖ហ៊ឺ!!!

ខ៖យកមកយើងអត់បានទៅទេរ៥ អ៊ីចឹងវាបានប៉ះស្ព័រហ្នឹងយកមកទុកទៅក្រែងលោរ ថាបើ ២១សិនជា ខែ៤ ហ្នឹងគេទៅគេដូរវាហាំ!! គេដូរវាគេអោយអ្នកផ្សេងទៅប៉ុន្តែវាបានប៉ះស្ព័រមក ហ្នឹងហើយគេអត់អោយទៅទេ គេខ្លាចវាទៅទៅ វារាំទៅវាផ្លៀតទៀតហាំ!!វាអត់ទាន់ជាហាំ!! ចុះខែ៤វាទៅហើយហ្នឹង វាបាក់ទឹមខែ២នេះហ្នឹង វានៅតែ២ខែទៀតវារាំម៉េចកើត។

ក៖ យ៉ាប់ម៉ង!!

ខ៖ អ៊ិចឹងហាំ វានៅផ្ទះទៅ ឥឡូវនៅតែផ្ទះហ្នឹង វានៅច្បារអំពៅហ្នំ!!!

ក៖ អញ្ចឹងបងសំរាប់ជីវិតរបស់បងតាំងពីតូចរហូតដល់ធំ ការងារអីគេខ្លះដែលបងធ្វើខ្លះ?

ខ៖ញ៉ុមហោ?

ក៖ចាំ!!

ខ៖ញ៉ុមពីតូចដល់ធំហ្នឹងការងារដល់ពេលមានប្តីទៅអត់មានធ្វើអីទេលក់អីទេ នៅតែផ្ទះ។

ក៖ ហ្នំអ៊ីចឹងស្វាមីអោយនៅស្រួលៗអីវ៉ាន់អញ្ចឹងដែរអញ្ចឹង!!

ខ៖ ហ្នឹងហើយ!នៅតែផ្ទះមើលតែកូនកាលនៅពីក្រមុំនឿយលក់នេះលក់នោះដើរជួលនំកង គេនំពងសងទូលដើរលក់ចំនេញបាន៤០០០ ៥០០០អីហ្នឹង បាន៤០០០៥០០០ហ្នឹងទិញបាន ខោអាវបានពីរបីកំផ្លេរហាំ!!

ក៖ ចាំសម័យមុន។

ខ៖ ពីមុនហាំ ទិញខោអាវបានពីរកំផ្លេរ ពីរកំផ្លេរហ្នឹងស្អាតណាស់ហើយអត់ហ៊ានពាក់ទៀត បត់ទុកចូលឆ្នាំចូលអីបានពាក់ គេថាខោអាវស្អាតៗហ្នែងមិនព្រមពាក់ហាំ !!ហោទុកហើយ អត់ហ៊ាន ពាក់ទេ!!ទុកពាក់ស្រលាញ់ណាស់ខោអាវ។

ក៖ ហើយបងមានដែលធ្វើស្រែចំការអីអត់ណាហី?

ខ៖ ហ៊ីបើបងស្រីញ៉ុមធ្វើ!!
ក៖ចា៎!!
ខ៖ បងស្រីញ៉ុមគាត់បានប្តីអ្នកធ្វើស្រែចំការអញ្ចឹងគាត់ធ្វើហើយញ៉ុមអត់ទេញ៉ុមអត់ដែលធ្វើអីផង ពេលញ៉ុមនៅពីក្មេងស្រណុករហូតហ្នឹងស្រណុកបើថាញ៉ុមមកនៅជាមួយយាយចិញ្ចឹមបានញ៉ុមបាននឿយ ព្រោះគាត់ចិញ្ចឹមញ៉ុមពេលម៉ែញ៉ុមស្លាប់ទៅហា៎!!
ក៖ ហើយម៉េចបានអត់ព្រមនៅជាមួយបងប្អូនហើយម៉េចបាននៅជាមួយគេវិញបង?
ខ៖ ណាមួយបងញ៉ុមគាត់ក្រដែរ
គាត់ចិញ្ចឹមបងប្អូនមិនសូវបានដែរគាត់មានគ្រួសារហើយណាមួយគាត់ខ្វះខាតដែរហា៎!!
ក៖ ចា៎!!
ខ៖ ហើយញ៉ុមយាយនោះគាត់ក៏អត់មានកូនមានអីដែរគាត់នៅតែឯងដែរហ្នឹងហា៎គាត់យកញ៉ុមមកចិញ្ចឹម ហ្នឹងហា៎!!ញ៉ុមនឹកឃើញអញ្ចឹងក៏នៅជាមួយយាយហ្នឹងទៅ គាត់វ៉ៃគាត់អីចេះតែនៅជាមួយគាត់អញ្ចឹងទៅ!! ហើយដល់ពេលគាត់ស្លាប់ទៅក៏គាត់ស្មាទោសញ៉ុមដែរ!! គាត់ដូចថាគាត់វ៉ៃយើងធ្វើបាបធ្វើអីយើងអញ្ចឹងទៅណាស់!!គាត់ថាគាត់ស្លាប់ទៅកុំអោយគាត់មានកម្មពៀរជាមួយយើងអីអញ្ចឹងទៅណាស់!!!
ក៖ ចា៎!ហើយគាត់ស្លាប់នៅហ្នឹងវត្តនឹងទៅ?
ខ៖ គាត់ស្លាប់នៅនឹងវត្តហ្នឹងទៅ នៅវត្តសំបួរមាស។
ក៖ អ៊ីចឹងបងមួយនេះគឺជាសំនួរមួយចុងក្រោយតើបងមានពាក្យពេចន៍អីគេខ្លះចង់ផ្តែផ្តាំកូនចៅជំនាន់ក្រោយអោយគាត់ ដើរលើផ្លូវអីគេដែរ អោយធ្វើជាមនុស្សអ៊ីចឹងម៉េចទៅណាស់?
ខ៖ ញ៉ុមសូមអោយកុំអោយដូចញ៉ុមពីជំនាន់ជំនាន់មុនអីអញ្ចឹងទៅណាស់អោយជំនាន់ក្រោយៗ វាបានកុំអោយដូចញ៉ុមពីមុនវេទនាដូចញ៉ុមអីអញ្ចឹងទៅណាស់ ដូចញ៉ុមពីមុនវេទនាណាស់ ឥឡូវជំនាន់នេះជំនាន់សប្បាយហើយទៅ ។
ក៖ហ៊ុំៗ!! មកដាំបាយដាំអីហូបអញ្ចឹងទៅណាស់ តែឥឡូវមិនបាច់ទេអង្ករល្មមៗអីអ្នកខ្លះអីមិនចង់ អង្ករល្មមៗអត់ហូបទេ ហូបតែអង្ករអីណា អង្ករល្អៗអីបានគេហូប។
ក៖ ចា៎ហ្នឹងហើយ បងអោយគាត់ដើរលើផ្លូវម៉េចដែរ?
ខ៖ អ្នកណាគេ?
ក៖ កូនហា៎!!
ខ៖កូនញ៉ុមហេ!!អោយកូនញ៉ុមហ្នឹងដើរនៅលើផ្លូវល្អទៅកុំអោយដើរលើផ្លូវអាក្រក់អីអ៊ីចឹងទៅណាស់!! អោយវាកុំអោយវាជក់ថ្នាំញៀនជក់អី កុំអោយវាអី តែអារឿងជក់វាជក់ មួយបាត់ហើយ។

កៈ មានដែរហេកូន?
ខៈ មាន បងគេបង្អស់ ។
កៈ ទៅរាំហ្នឹងហេ?
ខៈ អត់ទេអាបងគេបង្អស់ ។
កៈ ហ្ហូំ!!ហើយឥឡូវម៉េចដែរអត់មានអីណាហី?
ខៈ អាបងគេបង្អស់ញ៉ុមយកទៅដាក់នៅមណ្ឌលកែប្រែ បានវាញ៉ុមដាក់វាបានមួយឆ្នាំកន្លះ។
កៈ អោយលត់ដំនៅក្នុងហ្នឹងទៅ?
ខៈ ហ្នឹងហើយ ទៅទៅអញ្ចឹងទៅទៅមើលវាអញ្ចឹងទៅម៉ែអើយញ៉ុមលះបង់ហើយ
លះបង់ហើយម៉ែអើយញ៉ុមឈប់ធ្វើអញ្ចឹងហើយណាស់ ថាវាដាច់
វាដាច់គ្រឿងញៀនអីអញ្ចឹងទៅណាស់!!
កៈ ចាំ!!
ខៈទៅលេងវាម្តងៗដែរតើ!!
កៈនៅណាវិញទៅបងមណ្ឌលកែប្រែព្រៃសរហ្ហូំ!!ដាក់អោយឆ្ងាយនៅព្រៃសរហ្ហូំ!!តែនៅព្រៃសរហ្នឹងនេះដែរតើអត់អីទេ នៅព្រៃសរហ្នឹងទូរទស្សន៍ក៏មានមើល លុយមានលុយម៉ែម៉ែៗញ៉ុមសុំលុយដាក់កង្ហារ មួយខែ៥០០០។
កៈ ថោកម្ល៉េះ!!
ខៈ ញ៉ុមថាដាក់ទៅកង្ហារ។ ម៉ែទិញពូកដេកឥឡូវហើយ ពូគេប៉ុន្មាន១៥០០០០
ហើយដាក់គ្រែឥឡូវ គ្រែ១៥០០០០ដែរ!!នៅដាច់តែឯង។
កៈ តែមិនមែននៅក្នុងគុកណាហេបងអាហ្នឹង?
ខៈ នៅក្នុងគុកហ្នឹងបើយើងមានលុយយើងធ្វើអ្នកមាននៅក្នុងហ្នឹងហើយបើសិនជាយើងថាយើងប្រគល់អោយកូនយើង១០០នៅក្នុងហ្នឹងអញ្ចឹងហាំ!!យកអោយវាអញ្ចឹងហាំ!!វាចង់យកអីអោយហៅគេយកស្អីអោយវាក៏បានដែរគេបំរើវា។
កៈ ចំទៅអញ្ចឹងទៅ?
ខៈ ហ៊ឺ ចង់ហៅគេ ហៅជាងមកកាត់សក់ឬក៏ជាងកក់សក់ធ្វើក្រចកស្រីៗជាប់នៅនឹងស្អាតៗណាស់អូយញ៉ុមទៅម្តងៗញ៉ុមប្រាប់ទៅចេញមកសក់ត្រង់មកជួបម៉ែឪបងប្អូនអិចឹងហាំ!!សក់ឡើងត្រង់ក្រចកដៃម្រាមដៃឡើងស្រលូនៗហ្ហូំ!!
កៈ តែគ្រាន់តែថាអត់មានសេរីភាព?
ខៈ គ្រាន់តែថាអត់មានសេរីភាពដូចយើងដូចយើងដែរលេងអីអ៊ីចឹង។
កៈ អ៊ីចឹងឥឡូវឡើងបង់កូនមួយ !!តែឥឡូវបានប៉ុន្មានឆ្នាំហើយជាប់ហ្នឹង?

ខ៖ ហេបានប្រហែលជា៨ឆ្នាំហើយ ហាបាន៨ខែហើយច្រលំ នេះតាំងកូនញ៉ុមនេះកើតនេះ។
ក៖ហ្ហ៎!!
ខ៖កូនញ៉ុមចាប់កើតមកបានប្រហែលជាកន្លះខែវាចាប់មានរឿង។
ក៖ចា៎!!
ខ៖វាជក់គ្រឿងញៀនគ្រឿងអីគេចាប់ហា៎!!
ក៖ ចា៎!!
ខ៖ ហ្នឹងអាហ្នឹងបាន៨ខែចូលដល់ខែ៨។
ក៖ អ៊ីចឹងកូនចៅជំនាន់ក្រោយកុំយកគំរាបតាមបង។
ខ៖ កុំយកគំរាបតាមញ៉ុមអីអញ្ចឹងពីមុនអីអ៊ីចឹងហា៎!!អោយវាធ្វើអំពើល្អទៅវាមានលុយចាយអីអ៊ីចឹងទៅណាស់ រកស៊ីរកអីទៅដូចគេដូចឯងអីអ៊ីចឹងទៅ។
ក៖ កុំអោយទៅប្រព្រឹត្តអីផ្សេងៗដែលនាំអោយពិបាក។
ខ៖ ហ្នឹងហើយពេលមុនអីវេទនារកអីស៊ីចង់ងាប់ចង់រស់ទំរាំបានស៊ី
អាបាយផ្អមបាយអីក៏ចេះតែបបរស៊ីដែរហ្នឹងដូចពីមុនហា៎!!ក៖ ចា៎!!ខ៖
ច្របាច់ទៅលាងទឹកអោយស្អាតទៅដាក់កញ្ច្រែញទៅអោយស្រស់ទឹកទៅបបរទៅ
បងប្អូនហ្នឹងបបរស៊ីទៅ។
ក៖ ពេលម៉ែឪស្លាប់អញ្ចឹងទៅ?
ខ៖ ហ្នឹងហើយ បើបងៗគេទៅធ្វើស្រែធ្វើចំការគេអត់ទាន់បានមកផង។
ក៖ចា៎ហ្នឹងហើយអញ្ចឹងអរគុណបងសំរាប់ការសំភាសន៍ដែលបងបានរៀបរាប់ពីជីវិតអីអញ្ចឹងហា៎!!
ខ៖ ចា៎!!
ក៖ អរគុណច្រើនបង៕